# វាសនាកម្មការិនី

## The destiny of working women

Y Layyin

យប់យន់ចន្ទរះ រស្មីពណ៌មាស ពាសពេញពសុធា
ធម្មជាតិស្រស់ថ្លា តារានភា ភូមិភាគនានា
ដូចសួគ៌ាឋាន។

អារម្មណ៍កវី សោកសៅជួសស្រី មមៃតាមដាន
ស្រីច្រើនកន្លង មួហ្មងពេញប្រាណ ពាំភាពក្លាហាន
រុញច្រានជីវិត។

ទឹកភ្នែកស្រីខ្មែរ ក្រាបលាឪម៉ែ ស្រុកស្រែឆ្ងាយជិត
លាយាយលាតា ផ្សងវាសនាពិត អាណោចអាណិត
ដួងចិត្តទោរទន់។

កម្មករកាត់ដេរ មិនតិចតួចទេ ខំដេរពេកពន់
រាល់ថ្ងៃយប់ព្រឹក រោយស្លឹកស្រពន់ អាជីពស្រាលធ្ងន់
ទារុណលោកីយ៍។

គ្រឹះស្ថានរោងចក្រ ជួនជួបឧបសគ្គ កម្មករប្រុសស្រី
រឿងរ៉ាវតូចធំ យំប្រាប់កវី ជឿទេមន្ត្រី?
សម្ដីកម្មករ។

ប្រាក់ខែមិនគ្រប់ ការងារលើសលប់ ទប់ទល់ភាពក្រ
កំលាំងកាយស្រី បីដូចសំណរ ចិត្តរឹងដូចថ្ម
តស៊ូពុះពារ។

អស្ចារ្យណាស់ស្រី ខ្លះសរសៃខ្ចី រឹងរៃឥតរា
ផ្ញើកូននឹងគេ កាត់ដេរនឹកនា ស្រណោះបុត្រា
គ្រាំគ្រាគ្មានស្បើយ។

**អ៊ី ឡាយយិន**

លោកកើតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៦៧ នៅភូមិអូក្រឡាញ់ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ បច្ចុប្បន្ន លោកជាប្រជាពលរដ្ឋសាមញ្ញ។ ចាប់ពីឆ្នាំ១៩៩៧ រហូតមកដល់ឆ្នាំ២០០០ ស្នាដៃកំណាព្យដែលលោកបានផ្ញើទៅស្ថានីយ៍វិទ្យុអេហ្វអឹម ៩៩ និងអេហ្វអឹម ១០៣ ដើម្បីចាក់ផ្សាយមានប្រមាណជាង ៣០អត្ថបទ។

ស្រីខ្លះមានគភ៌ សាច់ស្លេកប្រែពណ៌ ញាប់ញ័រពេកហើយ
ជូនកូនរលូត ជូតទឹកភ្នែកឆ្លើយ កម្មការិនីអើយ
នេះហើយដើមទង។

គេបង្ខំពេក ស្រវាំងព្រិលភ្នែក ងើបឈរដួលត្លុង
ក្តៅរងារព្រឺ ជំងឺតាមលង អង្គុយលើសម៉ោង
ដុះឫសដូងបាត។

ខ្លះថប់ដង្ហើម ខ្លះស្រុងជើងហើម ឈឺចង់បាក់ស្បាត
បរិស្ថានស្មោគគ្រោក មេរោគរាតត្បាត រោងចក្រមិនស្អាត
នាំអាទិ៍រោគា។

ពុលក្លិនក្រណាត់ ហុយហប់ពេកក្តាត់ ពេញក្នុងអាគារ
រមាស់កន្ទួល ខ្សឹកខ្សួលវេទនា គេថាមាយា
និន្នាមានះ។

គួរអោយអាមាស់ ចោទគ្មានអៀនខ្មាស ទទឹសទទាស
សុំច្បាប់កាត់ប្រាក់ បាក់ចិត្តចង់ស្ទះ សារជាតិជារាស្រ្ត
បន់អោយព្រះជួយ។

ឈឺឈប់លប់ឈ្មោះ អត់អនុគ្រោះ ហួសហេតុដេកព្រួយ
ដកចេញដូចស្មៅ ថៅកែអាមួយ! កាចឆ្នាស់ដូចខ្មួយ
អាមួយអាហ៊ា!

ពេលខ្លះហត់ពេក លង់លក់ដំណេក ដេកភ្លេចមួយគ្រា
ខកម៉ោងបន្តិច ប្រទេចរាំងរា នាយឆ្មាំបញ្ជា
បិទទ្វាររបង។

| | | |
|---|---|---|
| ដូចមិនទំនង | កាត់ដេរលើសម៉ោង | ជាញឹកញយដង |
| ហេវចង់ខ្យល់គរ | ញើសហូរជោគខ្លួន | ត្រូវច្រើនខុសម្តង |
| | វិភាគផងទៅ! | |
| ខំចង់រលេះ | ចុកខ្នងចង្កេះ | ពិសេសយប់ជ្រៅ |
| ឈឺក្បាលវិលមុខ | ទុក្ខព្រួយពេកកូវ | រឹងរាំងរដូវ |
| | ម៉ែឪអត់ដឹង។ | |
| ស្រីភេទទន់ខ្សោយ | ឈឺជាក៏ដោយ | តែងតែខំប្រឹង |
| អស់ពីសមត្ថភាព | គួរជ្រាបគួរដឹង | បើមិនថ្លែងថ្លឹង |
| | អត់ដឹងហេតុផល។ | |
| បញ្ហាប្រាក់ខែ | សូមដំឡើងដែរ | នៅតែនឹងថ្កល់ |
| មិនស៊ីសង្វាក់ | ថវិកាគេផ្តល់ | ទូទាត់គ្មានសល់ |
| | ឆ្វល់ទេប្រាក់ខែ។ | |
| ចំណូលចំណាយ | កម្មករទាំងឡាយ | ខ្វះចាយគួញត្អែរ |
| ហូបចុកជួលផ្ទះ | ស្ទះស្មើរាល់ខែ | អស់ប្រាក់ផ្ញើម៉ែ |
| | អ្នកម៉ែសោកា។ | |
| ថ្លៃភ្លើងថ្លៃទឹក | សរុបសន្ធឹក | ព្រឹកល្ងាចអាហារ |
| បាយមួយចានស្រួប | ហូបគ្មានសក្តា | មិនស្តប់ម្តេចម្ការ |
| | ហើយធ្វើការទៀត។ | |
| បង្អែមចំណី | មិនសូវហ៊ានធី | ខ្សត់ខ្សោយជីវជាតិ |
| សន្សំសំចៃ | រាល់ថ្ងៃត្បិតត្បៀត | ផ្ទះជួលចង្អៀត |
| | ប្រជ្រៀតគ្នាដេក។ | |
| ស្រពោនស្រពាប់ | ស្រីខ្លះអភ័ព្វ | ឈឺញឹកញាប់ពេក |
| ទ្រាំទ្រមិនរួច | ព្រឺព្រួចអនេក | សម្រក់ទឹកភ្នែក |
| | ស្រែកលាពោងចក្រ។ | |

ទៅភូមិឋានវិញ ទាំងទុក្ខទោម្នេញ ចេញទាំងអន់អាក់
ជួបព្យុះព្យោមារ កម្មពៀរបង្អាក់ ដុនដាបអស់ប្រាក់
ពេទ្យឈប់ស្ទង់ស្ទាប ។

ស្តាយណាស់ជីវិត ព្រះព្រហ្មលិខិត ឱក្រិដ្ឋហួសប្រៀប
ព្រោះតែជំងឺ ឈឺគ្មានលទ្ធភាព នាងមរណភាព
អត់អ្នកសង្គ្រោះ។

ពុទ្ធោ! កម្មករ! អកុសលក្រ ត្រដាបត្រដួស
ទឹកខ្មៅកត់ត្រា ចារទុកនិទស្សន៍ មេរៀនអ្នករស់
រង្គោះដួងចិត្ត។

យុវមាណវី! ជាប់ជាអលជ្ជី ញាំញីមែនពិត
ទ្រាំតាមយថា ដុល្លារប្រសិទ្ធ ប្រឹងដល់កម្រិត
ខំឥតវៀចវេរ។

ព្រលឹមព្រលប់ ថែមម៉ោងថ្ងៃយប់ មិនហ៊ានឈប់ទេ!
ខួបខែខួបឆ្នាំ សកម្មកាត់ដេរ ប្អូនខ្ញុំប្អូនគេ
ទំនេរតិចណាស់។

ខ្លះចាញ់បោកគេ កំពុងកាត់ដេរ គេអោយប្រាក់កាស
ប្រលោមថ្នមថៃ សាងស្នេហ៍ផ្តេសផ្តាស ស្រីយល់មិនច្បាស់
ប៉ះចំប្រុសខូច។

ឆ្លងជំងឺអេដស៍ ចូលសំរាកពេទ្យ លន្លង់លន្លោច!
ពេទ្យមើលមិនជា ភាវនាងោចៗ រាគរូសច្រូចៗ
ដូចចាំមច្ចុរាជ។

សូមកុំភ្លើតភ្លើន ឃើញហើយកុំផ្តើន កើតចិត្តជោរនាច
ទឹកប្រាក់ជាធំ ទឹកឃ្មុំលាយលាច ហែហាមព្រឹកល្ងាច
មមាចក្រមុំ។

ប្រយ័ត្នប្រយែង គេយកជាល្បែង បន្លែងបន្លំ
អស់ព្រហ្មចារី រីងរៃទ្រព្យយំ ព្រះឥន្ទ្រព្រះព្រហ្ម
ក៏ជួយមិនបាន។

ខ្លះគ្មានការងារ ស្វែងរកគ្រប់គ្រា សព្វទិសទីឋាន
លឺគេប្រកាស អរណាស់ក្នុងប្រាណ សុំម៉ែឡើងឡាន
ជិះរករោងចក្រ។

ឆ្ងាយមិនមែនជិត! គ្មានខ្សែញាតិមិត្ត ល្អិតល្មោចសស្រាក់
មេខ្យល់បញ្ឆោត ស្រីឆោតស្លូកប្រាក់ ល្បិចល្បងស៊ីឡាក់
ហើយដាក់មេផាយ។

តរុណីខំស្រែក បង្ហូរទឹកភ្នែក អង្គុយដេកស្តាយ
វិលវិញវិយោគ រលកអង្គកាយ ព្រោះអីអ្នកម្តាយ
កើបកាយស្រូវលក់។

រឿងរ៉ាវមួយទៀត ស្រីចង់អត្តឃាត រសជាតិគំរក់
ចាញ់ឧបាយគេ មេបនទិញលក់ ថ្នាំញៀនបំពក់
វាយគក់ទក់សាច់។

កម្មកររាប់ពាន់ អ្នកខ្លះគ្រប់គ្រាន់ រួសរាន់បួបាច់
ថាមានប្រាក់ប៉ូវ បន្ថែមបំណាច់ គ្មានអ្នកកុងកាច់
ស្រេចលើថៅកែ។

មានក្រុមហ៊ុនខ្លះ បើកទៀងទាត់ណាស់ ប្រាក់ម៉ោងប្រាក់ខែ
ប្រាក់លើកទឹកចិត្ត គិតគួរហួរហែ អរគុណថៅកែ
ជួយខ្មែរដោយស្មោះ។

និយោជកល្អ យល់រឿងខ្មៅស បវរឥតខ្ចោះ
គោរពលក្ខខណ្ឌ ច្បាប់រដ្ឋទាំងអស់ មានធមិសប្បុរស
ចំពោះកុលស្រី។

| | | |
|---|---|---|
| មានការរាក់ទាក់<br>រិះគន់ស្ថាបនា | គួរអោយជឿជាក់<br>គ្មានការជេរស្តី<br>មានមេត្រីភាព។ | ពាក្យពេចន៍សម្តី<br>ពិតជាប្រពៃ |
| ថៅកែគំរូ<br>មិនប្រកាន់ផ្តាស | ចេះជួយគិតគូរ<br>យល់ណាស់សុខភាព<br>រៀបរយស្ងាត់ស្ងៀម។ | បន្ទូរស្ថានភាព<br>មានសុន្ទរភាព |
| នរៈកម្មករ<br>បើគ្មានរោងចក្រ | មានឆន្ទៈល្អ<br>គ្មានប្រាក់ត្រាំត្រៀម<br>នាមជាស្រីខ្មែរ។ | បន្តព្យាយាម<br>មិននៅទីមទាម |
| បើអត់ការងារ<br>ទ្រាំទៀតកុំថ្ងូរ | កម្មករគ្រប់គ្នា<br>ក្រែងលោថៅកែ<br>អោយបានសមរម្យ។ | ប្រហែលយ៉ាប់ដែរ<br>បន្ថែមប្រាក់ខែ |
| សច្ចាអត់ធន់<br>ទៅតាមរយៈ | បើភារៈធ្ងន់<br>ភ្នាក់ងារមេក្រុម<br>កុំទុកពន្យារ។ | ធ្វើញត្តិស្នើសុំ<br>វិបត្តិតូចធំ |
| រោងចក្រថ្មីចាស់<br>បើម្ចាស់បំពាន | ជ្រួតជ្រាបអោយច្បាស់<br>យើងហ៊ានទាមទារ<br>ថៅកែកម្មករ។ | ច្បាប់កម្ពុជា<br>មានសិទ្ធិដូចគ្នា |
| មានសហជីព<br>កុំផ្ទៀងម្ខាងៗ | អ្នកជាប្រទីប<br>តំណាងកម្មករ<br>កម្មករស្រលាញ់។ | មើលភាពខ្មៅស<br>ជញ្ជីងច្បាប់ល្អ |
| ដោះស្រាយបញ្ហា<br>ដោយសិល្បវិធី | កុំប្រើអាជ្ញា<br>ភាគីខ្ជួលខ្វាញ់<br>គ្មានអ្នកផ្ទាញ់ផ្ទាល។ | កម្លាប្រវិញ<br>ទៅមុខត្របាញ់ |

មានសាមគ្គីភាព តទៅរៀងរាប ជីវភាពដុះដាល
ឈប់បាតុកម្ម ឡាំប៉ាអុជអាល រដ្ឋាភិបាល
ជួយសំរាលផង។

កម្មករទាំងឡាយ! ទាំងជិតទាំងឆ្ងាយ ស្រាយចិត្តម្ហូហ្មង
ឈប់យំឈប់ស្រែក! ហែកហួរឱ៍ដង ខ្ទាសសាសន៍គេផង
ក្រុមកាសែតចុះ។

ក្អែកមួយក្អែកដប់ ទំនាស់មិនចប់ បំផុលបំផុស
នាំអោយប្រេះស្រាំ រកាំរកូស! ព័ត៌មានសាយសុះ
កំហុសអ្នកណា?

កម្មការិនី រួបរួមមូលមី គិតគូរកិច្ចការ
ពុកម្តាយនៅស្រុក សំកុកចាំណាំ! កុំតូចចិន្តា
សេវាថោកថ្លៃ! ។

ឱ! ស្ត្រីខ្មែរអើយ ឱកាសនេះហើយ អ្នកមានតំលៃ
កុំធ្វេសប្រហែស ជិះសេះលែងដៃ បំផាយយប់ថ្ងៃ
ចរណៃត្រូវខំ! ។

រស់លើលោកា រង់ចាំវាសនា ដូចមេឃស្រទំ
កុំចាំថ្ងៃរះ មាសប្រាក់ក្តោងធំ វាតចិត្តអោយធំ
ទ្រនំជនបទ។

សូមផ្ញើសំដី ទឹកខ្មៅភក្តី ជូនស្រីកម្សត់
បើខ្វះលើសល្អស ហួសដែនកំណត់ សុំទោសប្រាកដ
តាមបទនិពន្ធ។

គោរពជូនពរ តាមខ្យល់ជំនោរ ពុទ្ធិពរមានមន្ត
កុលបុត្រប្រុសស្រី សិរីជោរជន់ មាសប្រាក់ទ្រព្យធន
ជន់ចូលទៅអើយ។